NORTHBRIDGE INTERNATIONAL SCHOOL CAMBODIA
A NORD ANGLIA EDUCATION SCHOOL

P.O. Box 2042, Phnom Penh 3, Cambodia +855 (0)23 900 749
admissions@nisc.edu.kh
northbridgecambodia
northbridgecambodia
www.nisc.edu.kh

# តារាងតម្លៃសិក្សា: 2026-2027

តារាងនៃតម្លៃសិក្សានេះ គឺយោងតាមកិច្ចព្រមព្រៀងដាក់ពាក្យចូលរៀន ហើយសំរាប់ខ្លឹមសារលម្អិតគឺមានចែងនៅក្នុងកិច្ចព្រមព្រៀងដាក់ពាក្យចូលរៀន។

តម្លៃសិក្សាសម្រាប់ឆ្នាំសិក្សា 2026 ដល់ 2027 មានដូចខាងក្រោមៈ

**តម្លៃដាក់ពាក្យ (សម្រាប់តែសិស្សថ្មីប៉ុណ្ណោះ)** — **$290** *EL2-12*

សិស្សថ្មីដែលមានបំនងចង់ដាក់ពាក្យចូលរៀនទាំងអស់ត្រូវបង់ថ្លៃដាក់ពាក្យ សម្រាប់ដំណើរការ និងការធ្វើតេស្តចូលរៀន។ ការបង់ប្រាក់នឹងត្រូវទូទាត់ នៅពេលទម្រង់ដាក់ពាក្យចូលរៀននីមួយៗបានបំពេញរួច និងមិនអាចបង្វិលជូនវិញបន្ទាប់ពីបានទូទាត់រួចរាល់។

**តម្លៃចុះឈ្មោះ (សម្រាប់តែសិស្សថ្មីប៉ុណ្ណោះ)** — **$850** *EL2, EL3 & EL4*; **$2,990** *KG-12*

សម្រាប់សិស្សថ្មីចាប់ពីថ្នាក់មុនមត្តេយ្យEL2 ដល់ ថ្នាក់ទី១២ ត្រូវបង់ថ្លៃចុះឈ្មោះជាមុនសិន។ ថ្លៃចុះឈ្មោះនេះមិនមានបង្វិលជូនវិញ និងមិនអាចផ្ទេរទៅកាន់សិស្សផ្សេង ហើយតម្រូវឱ្យទូទាត់ជូននៅពេលសាលាទទួលសិស្សឱ្យចូលរៀន។
*សូមចំណាំថាមានថ្លៃផ្លាស់ប្តូរឡើងថ្នាក់បន្ថែមចំនួន $1,500 នៅពេលសិស្សឡើងពីថ្នាក់មុនមត្តេយ្យ EL4 ទៅថ្នាក់មត្តេយ្យ KG ។

**ប្រាក់តម្កល់ (សម្រាប់តែសិស្សថ្មីប៉ុណ្ណោះ)** — **$1,000** *EL2-12*

សម្រាប់សិស្សថ្មីចាប់ពីថ្នាក់មុនមត្តេយ្យ EL2 ដល់ ថ្នាក់ទី១២ ត្រូវបង់ប្រាក់តម្កល់។ សាលានឹងបង្វិលជូនវិញ ក្នុងលក្ខខណ្ឌដែលទម្រង់សុំបញ្ចប់ការសិក្សារបស់សិស្ស ត្រូវបានដាក់ស្នើក្នុងរយៈពេលជូនដំណឹង 60 ថ្ងៃមកខាងសាលា។

**ថ្លៃបរិក្ខារប្រចាំឆ្នាំ (សិស្សថ្មី និងសិស្សនៅកំពុងសិក្សា)** — **$1,440** *EL2, EL3 & EL4*; **$2,840** *KG-12*

សិស្សទាំងអស់តម្រូវអោយទូទាត់ថ្លៃបរិក្ខារប្រចាំឆ្នាំ ដើម្បីរ៉ាប់រងលើការចំនាយក្នុងការថែទាំ ជួសជុល និងពង្រឹងគុណភាពអគារសាលា និងគ្រឿងបរិក្ខារជាប្រចាំឆ្នាំ។ មិនមានការបង្វិលជូនវិញសំរាប់ថ្លៃប្រចាំឆ្នាំ និងមិនអាចផ្ទេរបានទៅកាន់សិស្សផ្សេងទៀត ហើយតម្រូវឱ្យទូទាត់គ្រប់ចំនួនមុនសិស្សចាប់ផ្តើមចូលរៀន។ សិស្សដែលចុះឈ្មោះសម្រាប់ឆមាសទីពីរត្រូវបង់ត្រឹម50% នៃថ្លៃប្រចាំឆ្នាំ។

**តម្លៃសិក្សា (សិស្សថ្មី និងសិស្សនៅកំពុងសិក្សា)**

| ជម្រើសការទូទាត់ | ប្រចាំឆ្នាំ | ឆមាស (ការទូទាត់ពីរដង) | | ត្រីមាស (ការទូទាត់បួនដង) | | | |
|---|---|---|---|---|---|---|---|
| GRADE LEVEL | 7 JUL 26 | 7 JUL 26 | 11 DEC 26 | 7 JUL 26 | 1 OCT 26 | 11 DEC 26 | 5 MAR 27 |
| EARLY LEARNING 2-4 | $11,550 | $5,950 | $5,950 | $3,032 | $3,032 | $3,032 | $3,032 |
| KG TO GRADE 1 | $21,815 | $11,230 | $11,230 | $5,726 | $5,726 | $5,726 | $5,726 |
| GRADE 2 - 5 | $22,795 | $11,740 | $11,740 | $5,984 | $5,984 | $5,984 | $5,984 |
| GRADE 6 - 8 | $27,975 | $14,410 | $14,410 | $7,343 | $7,343 | $7,343 | $7,343 |
| GRADE 9 - 10 | $28,295 | $14,570 | $14,570 | $7,427 | $7,427 | $7,427 | $7,427 |
| GRADE 11-12 | $30,475 | $15,690 | $15,690 | $7,998 | $7,998 | $7,998 | $7,998 |

| ថ្លៃសិក្សារួមបញ្ចូលដូចខាងក្រោម | |
|---|---|
| ✓ | សៀវភៅពុម្ព និងសៀវភៅសរសេរ |
| ✓ | សិស្សថ្មី:<br>ឈុតកីឡា (PE) ចំនួន 2 ឈុត (អាវ និងខោខ្លី), ដបទឹក 1, កាបូប 1, មួក 1 (សម្រាប់តែសិស្សបឋមសិក្សា), អាវក្រុមក្នុងសាលា 1 |
| ✓ | ទស្សនកិច្ចសិក្សាដែលតម្រូវអោយសិស្សចូលរួម (ស្នាក់នៅ ឬរិលល្ងាច) |

*ថ្លៃសេវាបន្ថែមរួមមាន៖ សកម្មភាពបន្ថែមក្រៅម៉ោងសិក្សា *LEAP*, ថ្លៃប្រឡង *IB*, ទស្សនកិច្ចសិក្សាដែលសិស្សមានបំនងចូលរួម, ថ្លៃឡានសាលា និងសេវាកម្មជំនួយការសិក្សា *(EAL* និង *SEN)*

NORTHBRIDGE INTERNATIONAL SCHOOL
CAMBODIA
A NORD ANGLIA EDUCATION SCHOOL

P.O. Box 2042, Phnom Penh 3,
Cambodia +855 (0)23 900 749
admissions@nisc.edu.kh
northbridgecambodia
northbridgecambodia
www.nisc.edu.kh

## ការបញ្ចុះតម្លៃសម្រាប់បងប្អូនបង្កើត

ការបញ្ចុះតម្លៃសម្រាប់បងប្អូនបង្កើត អាចត្រូវបានផ្តល់ជូនចាប់ពី **សិស្សបីនាក់ ឬច្រើនជាងនេះ** មកពីគ្រួសារតែមួយ និងចូលរៀនក្នុងពេលតែមួយ ដោយទទួលបានការបញ្ចុះតម្លៃ 5% សម្រាប់កូនទី 3 និង 10% សម្រាប់កូនទី 4 និងលើសពីនេះ។ ការបញ្ចុះតម្លៃជាភាគរយនេះ គឺទៅលើថ្លៃសិក្សារបស់សិស្សដែលមានអាយុតិចជាងគេ។

## ថ្លៃសេវាកម្មផ្សេងៗ

### សេវារថយន្តដឹកសិស្ស (ជម្រើស)

សាលាមានផ្តល់ជូនសេវារថយន្តដឹកសិស្ស សម្រាប់សិស្សដែលមានបំណងចង់ទទួលបាននូវ ការដឹកជញ្ជូនទៅ និងមកប្រចាំថ្ងៃ។ ជំរើសនៃការបង់មានប្រចាំឆ្នាំ ឬឆមាស។ ថ្លៃសេវាដឹកសិស្ស មិនអាចបង្វិលជូនវិញបន្ទាប់ពីបានបង់រួច នឹងមិនអាចផ្ទេរបានសិស្សដទៃឡើយ ហើយតម្រូវឱ្យទូទាត់គ្រប់ចំនួនជាមុនទៅតាមកាលបរិច្ឆេទ ស្របតាមជម្រើសនៃការបង់ដែលបានព្រមព្រៀង។

**តម្លៃសេវារថយន្តដឹកសិស្ស៖**
**ពេញមួយឆ្នាំ $2,300**
**ឆមាស $1,150**

### សេវាកម្មជំនួយការសិក្សា

សាលាមានផ្តល់សេវាកម្មជំនួយការសិក្សាដល់សិស្សដែលមានថ្លៃបន្ថែមដូចខាងក្រោម៖

**ក.** ថ្នាក់ជំនួយភាសាអង់គ្លេសបន្ថែម (EAL) សម្រាប់សិស្សដែលភាសាអង់គ្លេសមិនមែនជាភាសាពីកំនើត។ នៅក្នុង EAL, Accelerated Language Support (ALS) ផ្តល់នូវការសិក្សាភាសាអង់គ្លេសដែលមានគុណភាពខ្ពស់ ល្អិតល្អន់ និងផ្តោតសំខាន់ទៅលើសិស្សដែលកំរិតភាសាអង់គ្លេសមានកំនត់។ ថ្លៃសេវាក្នុងមួយឆមាសគឺ **$2,195** សម្រាប់កម្រិត 3 និង **$1,250** សម្រាប់កម្រិត 2 ។

**ខ.** សេវាកម្មតម្រូវការអប់រំពិសេស (SEN) សំរាប់សិស្សដែលមានតម្រូវការអប់រំពិសេស បន្ថែមពីលើការរៀនក្នុងថ្នាក់ធម្មតា។ ការដាក់សិស្សក្នុងកម្មវិធី SEN ត្រូវបានកំណត់ដោយសាលា តាមកិច្ចព្រមព្រៀងនៃការចុះឈ្មោះចូលរៀន ហើយមានតម្លៃ **$5,500** ក្នុងមួយឆ្នាំសិក្សា។

កម្រិតថ្នាក់ជំនួយសម្រាប់ *EAL* និង *SEN* ត្រូវបានកំណត់ដោយសាលា ហើយនឹងត្រូវបានជូនដំណឹងទៅកាន់ឪពុកម្តាយដោយផ្ទាល់ជាមុន។

## លក្ខខណ្ឌសម្រាប់ការបង់ថ្លៃសិក្សា

**1. ការពិន័យលើការទូទាត់យឺត៖** ថ្លៃសិក្សាទាំងអស់ត្រូវបង់តាមកាលបរិច្ឆេទដែលបានបញ្ជាក់ ។ ការទូទាត់យឺតយ៉ាវពីរ (2) សប្តាហ៍នឹងត្រូវគិតថ្លៃពិន័យ 5% បន្ថែម; និងការពិន័យ 1% បន្ថែមទៀតក្នុងមួយសប្តាហ៍នឹងត្រូវអនុវត្តចំពោះចំនួនទឹកប្រាក់ដែលនៅសេសសល់លើសពីកាលបរិច្ឆេទនោះ។ ការមិនបង់ថ្លៃសិក្សា អាចប្រឈមមុខនឹងការ មិនទទួលសិស្សឱ្យចូលរៀន ឬការព្យួរការសិក្សាដោយមិនមានការចេញជូននូវរបាយការណ៍សិក្សា និងពិន្ទុ។

**2.** ការទូទាត់* អាចត្រូវបានធ្វើឡើងតាមវិធីដូចខាងក្រោម៖
- ក) ការផ្ទេរប្រាក់តាមធនាគារទៅកាន់គណនីធនាគាររបស់សាលា
- ខ) មូលប្បទានប័ត្រប្រាក់ដុល្លារអាមេរិកដែលដកចេញពីធនាគារនៅរាជធានីភ្នំពេញ
- គ) កាតឥណទាន (អ្នកបង់ប្រាក់ត្រូវទទួលខុសត្រូវចំពោះថ្លៃសេវាទាំងអស់)

*ការបង់ជាសាច់ប្រាក់ត្រូវបានទទួលយកសម្រាប់សមតុល្យមិនលើសពី 1,000 ដុល្លារ

ចំណាំទី 1: រាល់សេវាថ្លៃផ្ទេរប្រាក់តាមធនាគារជាទំនួលខុសត្រូវរបស់ភាគីអ្នកផ្ទេរប្រាក់។
ចំណាំទី 2: សាលាមិនទទួលយកការទូទាត់ពីគណនីធនាគារដែលត្រូវបានដាក់ទណ្ឌកម្ម អនុម័តតាម sanctionssearch.ofac.treas.gov ឬការទូទាត់ដែលមកពីទឹកដី និងប្រទេសដែលត្រូវបានដាក់ទណ្ឌកម្មនោះទេ។
ចំណាំទី 3: រាល់ក្រដាសប្រាក់ណាមួយដែលត្រូវបានកំណត់ថាជាការក្លែងបន្លំ – មិនថាដោយ សាលាឬដោយធនាគារដែលបានចុះបញ្ជីរបស់យើង គ្រួសារដែលបានផ្តត់ផ្គង់ក្រដាសប្រាក់មានទំនួលខុសត្រូវក្នុងការប្តូរជំនួសនូវក្រដាសប្រាក់ដែលត្រឹមត្រូវសម្រាប់ការទូទាត់។

**3.** ថ្លៃសិក្សាមិនត្រូវបានបង្វិលសង ឬផ្ទេរទៅកាន់សិស្សផ្សេងទៀតទេ ទោះក្នុងលក្ខខណ្ឌសិស្សមិនបានសិក្សាពេញមួយត្រីមាសក៏ដោយ។ ចំពោះសិស្សថ្មី តម្រូវអោយបង់ថ្លៃសិក្សាពេញមួយត្រីមាសដែលពួកគេចាប់ផ្តើមសិក្សាទោះចាប់ផ្តើមសិក្សាក្នុងថ្ងៃណាមួយនៃត្រីមាសក៏ដោយ។ ថ្លៃសេវាទាំងអស់ត្រូវទូទាត់គ្រប់ចំនួនមុនពេលការសិក្សាចាប់ផ្តើម។

**4. ការសុំបញ្ឈប់ការសិក្សា**
មាតាបិតាមានទំនួលខុសត្រូវក្នុងការបំពេញលិខិតសុំដកសិស្សចេញតាមកិច្ចព្រមព្រៀងរបស់សាលា ហើយប្រគល់ទៅការិយាល័យចុះឈ្មោះយ៉ាងហោចណាស់ 60 ថ្ងៃមុនថ្ងៃសិក្សាចុងក្រោយរបស់សិស្សនៅក្នុងសាលា ដើម្បីធានាថាគោលការណ៍សងប្រាក់ត្រូវបានអនុវត្ត ហើយរបាយការណ៍សិក្សាត្រូវបានផ្តល់ជូន ។ឧទាហរណ៍ នៅពេលដែលសិស្សចាកចេញនៅចុងឆមាសទី 1 មាតាបិតាត្រូវជូនដំណឹងទៅសាលា 60 ថ្ងៃមុនថ្ងៃសិក្សាចុងក្រោយនៃឆមាសទី 1

**5.** សម្រាប់ការឈប់សិក្សាក្នុងអំឡុងឆ្នាំសិក្សាដោយមានការស្នើសុំជាលាយលក្ខណ៍អក្សរ ការបង្វិលជូនវិញនូវថ្លៃសិក្សាដែលបានបង់រួចនឹងត្រូវបានផ្តល់ជូនក្នុងតម្លៃ 90% នៃត្រីមាសដែលសិស្សមិនទទួលបានការសិក្សា - ប៉ុន្តែមិនមានជាសំណងសំរាប់ត្រីមាសដែលសិស្សកំពុងសិក្សានោះទេ ។ ថ្លៃបរិក្ខារប្រចាំឆ្នាំ នឹងមិនត្រូវបង្វិលសងវិញនោះទេនៅពេលសិស្សចាកចេញក្នុងអំឡុងឆ្នាំសិក្សា។

**6.** ពន្ធអាករតម្លៃបន្ថែមនឹងត្រូវបូកទៅលើថ្លៃសិក្សាដែលបានរៀបរាប់ខាងលើ នៅពេលដែលច្បាប់តម្រូវអោយសាលាបង់ពន្ធជូនរដ្ឋ។

**7.** ក្នុងករណីប្រធានសក្ក (កត្តាធម្មជាតិ ឬព្រឹត្តការណ៍ដែលមិនអាចទប់ស្កាត់បាន) ដែលរារាំងដល់ការផ្តល់ការអប់រំក្នុងសាលាសម្រាប់រយៈពេលមួយសប្តាហ៍ ឬយូរជាងនេះ សាលាអាច និង/ឬ ផ្តល់ការគាំទ្រពិសេសណា១ដល់មាតាបិតាសំរាប់ពេលមួយដង។ វិធានការដែលអាចផ្តល់ដើម្បីគាំទ្រដល់មាតាបិតានឹងត្រូវបានកំណត់ និងជូនដំណឹងដល់លោកអ្នកនៅពេលប្រធានសក្កបានកើតឡើង។ ដំណោះស្រាយដែលនឹងផ្តល់ជូន រួមមានការផ្តល់ការបង្រៀនតាមប្រព័ន្ធអ៊ីនធើណេតជាដើម អាស្រ័យលើកាលៈទេសៈនៃព្រឹត្តិការណ៍ពាក់ព័ន្ធ រយៈពេលដែលកើតឡើង និងឆ្នាំសិក្សាដែលរងផលប៉ះពាល់។